# ព្រះរាជក្រម

នស/រកម/០២៩៧/០៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា ទទួល
លេខ.....១៦១៩.............
ថ្ងៃទី១០.០២.៩៧ម៉ោង៤ល្ងាច
បញ្ជូនទៅ...................

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីតិសម្បទា និង អភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការលើកទឹកចិត្តវិនិយោគរវាងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក និង រាជរដ្ឋាភិបាលកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ មករាឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការលើកទឹកចិត្តវិនិយោគ រវាងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិកនិងរាជរដ្ឋាភិបាលកម្ពុជា

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការលើកទឹកចិត្តវិនិយោគរវាងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិកនិងរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើនៅភ្នំពេញនាថ្ងៃ ០៤ ខែ សីហា ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ ១៩៩៧

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិ
សម្បទានិងអភិវឌ្ឍន៍និងជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**